# របាយការណ៍លទ្ធផល
# ស្តីពី
# ការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៧
# វិទ្យាស្ថានជាតិអប់រំ

## សេចក្តីផ្តើម

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី ទិវាជាតិអំណាន។ ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់សហការជាមួយក្រសួងពាក់ព័ន្ធ និងអង្គការដៃគូអភិវឌ្ឍ បានរៀបចំប្រារព្ធពិធីតាមខ្លឹមសារក្នុងអនុក្រឹត្យពុំលែងឡើយ។ ជាក់ស្តែង នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំប្រារព្ធទិវាជាតិអំណានលើកទី១ នៅសាលប្រជុំសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដោយមានអ្នកចូលរួមមកពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្នុងពិធីនោះមានកម្មវិធីអានអត្ថបទ និងសូត្រកំណាព្យជានិមិត្តរូប។ ដោយឡែកនៅឆ្នាំ២០១៧ ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី២ មានទិដ្ឋភាពធំជាងលើកទី១ ដោយក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍពាក់ព័ន្ធ និងមានការចូលរួមរបស់អង្គភាពក្រោមឱវាទ ទីស្តី ការក្រសួង និងមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ចូលរួម។ ក្នុងពិធីនោះ មានកម្មវិធីប្រឡងប្រជែងអាន និងសូត្រកំណាព្យសម្រាប់ទទួលជ័យលាភី ពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** ព្រមទាំងប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បេក្ខជនជ័យលាភី លេខ១ លេខ២ និងលេខ៣ និងមានរៀបចំជាស្តង់សម្រាប់ការតាំងបង្ហាញ ពីឯកសារទាំងឡាយរបស់ក្រុមហ៊ុន អង្គការដៃគូរ និងឯកសារសមិទ្ធិផលអប់រំដែលបានអភិវឌ្ឍកន្លងមក ។

## I. គោលបំណង

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំប្រារព្ធទិវាជាតិអំណានឆ្នាំ២០១៧ ជាលើកទី២នេះឡើង ក្រោមប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** " ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពអាន សូត្រកំណាព្យ និងការតែងនិពន្ធ ដើម្បីរួមចំណែកការពារ និងពង្រឹងវប្បធម៌ខ្មែរ។

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានឆ្នាំ២០១៧នេះ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីសម្រេចលេខ ០៨ អយក.អកស ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៧ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន។ ក្នុងការបំពេញបេសកកម្មនេះ គណៈកម្មការបានសហការជាមួយក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធមានដូចជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រុមប្រឹក្សាជាតិភាសាខ្មែរ រាជបណ្ឌិត្យសភាកម្ពុជា សមាគម អ្នកនិពន្ធខ្មែរ ក្នុងការបង្កើតជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុដល់បេក្ខជនប្រឡងអាន និងសូត្រកំណាព្យ និងដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ មានដូចជា អង្គការយូណេស្កូ អង្គការថ្លែនអន្តរជាតិ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ អង្គការSipar អង្គការSVA អង្គការRoom to Read អង្គការChild Fund cambodia អង្គការSave the Children សាកលវិទ្យាល័យបញ្ញាសាស្ត្រ បណ្ណាល័យបញ្ញាវន្ត និងអង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា ក្នុងការសហការរៀបចំ និងឧបត្ថម្ភ។ ដំណើរការនៃការរៀបចំពិធីទិវាជាតិអំណានបានប្រព្រឹត្តទៅតាមសកម្មភាព២ គឺ សកម្មភាពមុនការប្រារព្ធពិធី និងការប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ២០១៧ ។

- សកម្មភាពមុនការប្រារព្ធពិធី ៖ ជាការរៀបចំផែនការសកម្មភាពសម្រាប់រៀបចំទិវាជាតិអំណាន និងការប្រជុំរបស់ក្រុមការងាររៀបចំទិវាជាតិអំណានជាមួយថ្នាក់ដឹកនាំក្រសួង ។

- សកម្មភាពការប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ២០១៧ ជាការរៀបចំសកម្មភាពរយៈពេល០៣ថ្ងៃ ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ ក្នុងនោះមាន ៖

- កម្មវិធីប្រឡងប្រជែងការអាន និងសូត្រកំណាព្យ ដើម្បីដណ្ដើមជ័យលាភី លេខ១ លេខ២ និងលេខ៣ ដើម្បីទទួលពានរង្វាន់ **សម្ដេចតេជោ ហ៊ុន សែន** ។ បេក្ខជនក្នុងកម្មវិធីប្រឡងប្រជែង ជាបេក្ខជនដែល២៥ រាជធានី ខេត្ត បានធ្វើការប្រឡងប្រជែងនិងសម្រិតសម្រាំងរួចហើយក្នុងក្របខណ្ឌរាជធានី ខេត្តនីមួយៗ និងបានបញ្ជូនមកចូលរួមប្រឡងប្រជែងថ្នាក់ជាតិ នៅវិទ្យាស្ថានជាតិអប់រំ។

- កម្មវិធីតាំងស្ដង់បង្ហាញពីឯកសារជាសមិទ្ធិផលរបស់វិស័យអប់រំ និងសមិទ្ធិផលជាស្នាដៃរបស់ អង្គការជាតិ អន្តរជាតិ និងក្រុមហ៊ុនផ្សេងៗ ។

- កម្មវិធីប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៧ មាន ការថ្លែងសុន្ទរកថា របស់លោកស្រីប្រធានអង្គការ យូណេស្កូ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន លោកជំទាវរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បទបង្ហាញរបស់លោកជំទាវអនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ការអាន និងសូត្រកំណាព្យរបស់បេក្ខជនជ័យលាភី និងការប្រគល់ពានរង្វាន់សម្ដេចតេជោ **ហ៊ុន សែន** និងប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បេក្ខជនជ័យលាភីលេខ១,២,៣ និងវេទិកាអំណាន និងការពិភាក្សាលើប្រធានបទទាក់ទងនឹងទិវាជាតិអំណាន។

## III.សកម្មភាពនៃការរៀបចំទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៧

### ១-សកម្មភាពមុនការប្រារព្ធពិធីទិវាជាតិអំណាន

ជាការត្រៀមរៀបចំសម្រាប់សកម្មភាពទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ។ សកម្មភាពត្រៀមរៀបចំ មានលក្ខណៈបន្តបន្ទាប់ដូចខាងក្រោម ៖

#### ក-កិច្ចប្រជុំថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥

អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **លោកជំទាវ ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងលោក លោកស្រី មកពីនាយកដ្ឋានក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងដៃគូអភិវឌ្ឍ សរុបចំនួន ៣១ នាក់។ លទ្ធផលនៃកិច្ចប្រជុំមាន ៖

- ពិនិត្យ និងកែលម្អ ចប់ជាស្ថាពរ សេចក្តីព្រាង សារាចរ ស្តីពី ការប្រារព្ធទិវាជាតិអំណាន ១១ មីនា
- មន្ត្រីជំនាញ ត្រូវសហការជាមួយភាគីពាក់ព័ន្ធ ជ្រើសរើសប្រធានបទមួយដែលសមស្របសម្រាប់ទិវាជាតិអំណាន ១១ មីនា ២០១៧។
- ការស្នើឱ្យមានការរៀបចំបោះពុម្ពអាវយឺតសម្រាប់ការប្រារព្ធពិធី

#### ខ-កិច្ចប្រជុំថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៦

អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិត ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លោក លោកស្រី អញ្ជើញមកពីនាយកដ្ឋានក្រោមឱវាទក្រសួងសរុបចំនួន ៣៥ នាក់។ លទ្ធផលនៃកិច្ចប្រជុំមាន ៖

- ការកំណត់ចំនួនបេក្ខជនជ័យលាភី គឺក្នុង១ រាជធានី ខេត្ត មានចំនួន ៣ នាក់
- ការកំណត់កាលបរិច្ឆេទទិវាជាតិអំណាន គឺថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧
- ទីកន្លែងប្រារព្ធពិធី វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- អង្គពិធីស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន**

- សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រាជបណ្ឌិត្យសភាកម្ពុជា និងសមាគមអ្នកនិពន្ធខ្មែរ ។

**គ-កិច្ចប្រជុំថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧**

អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម បណ្ឌិត ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា លោក លោកស្រី អញ្ជើញមកពី អគ្គនាយកដ្ឋាន និងនាយកដ្ឋានក្រោមឱវាទក្រសួងសរុបចំនួន ៣៣ នាក់។ លទ្ធផលនៃកិច្ចប្រជុំមាន ៖

- ការកំណត់កាលបរិច្ឆេទប្រារព្ធពិធីជាតិអំណានគឺ ថ្ងៃទី១១ មីនា ២០១៧
- ទីកន្លែង វិទ្យាស្ថានជាតិអប់រំ
- សមាសភាពចូលរួម ១១០០ នាក់
- ប្រធានបទទិវាជាតិអំណាន " **អានដើម្បីភាពសុខដុមនៃជីវិត** " និងពាក្យស្លោកចំនួន៦ ( អានដើម្បីភាពសុខដុមនៃជីវិត អំណានជាស្ពានៃជីវិត អំណានដើម្បីការអភិវឌ្ឍ អានហើយអានទៀតអានពេញមួយជីវិត អានច្រើនកើនប្រាជ្ញា អំណានជាភាពជោគជ័យក្នុងជីវិត ) ។
- ការរៀបចំវីដេអូឃ្លីបពីសកម្មភាពអាន និងចំណាប់អារម្មណ៍របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ប្រធានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ប្រធានអង្គការរូមធូរីដ ប្រធានអង្គការយូណេស្កូ
- ការរៀបចំស្តង់តាំងពិព័រណ៍តាមស្ថានភាពជាក់ស្តែង
    - ការជ្រើសរើសជ័យលាភីពីលេខ១ ដល់លេខ៣ ( អត្ថបទ ដកស្រង់ចេញពីកម្មវិធីសិក្សា)
    - ទំនាក់ទំនងជាមួយអង្គការដៃគូ ក្នុងការចូលរួមឧបត្ថម្ភគាំទ្រ
    - នាយកដ្ឋានរដ្ឋបាល ជាអ្នកទទួលខុសត្រូវរៀបចំលិខិតអញ្ជើញ

**ឃ-ផែនការសកម្មភាពរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៧**

ខ្លឹមសារនៃផែនការសកម្មភាពមានដូចខាងក្រោម ៖

I. ការរៀបចំលិខិតបទដ្ឋានគតិយុត្តិ

II. គម្រោងផែនការការងារ និងផែនការថវិកា

III. សកម្មភាពប្រជុំ

IV. ការផ្សព្វផ្សាយ

V. កំណត់ហេតុ និងរបាយការណ៍ការងារ

ខ្លឹមសារនៃផែនការសកម្មភាពនេះ ត្រូវបានរៀបចំដោយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្នុងនោះមានបង្ហាញពីពេលវេលាអនុវត្ត អ្នកទទួលខុសត្រូវ (នាយកដ្ឋាននីតិកម្ម រដ្ឋបាល អភិវឌ្ឍកម្មវិធីសិក្សា និងព័ត៌មាន និងកិច្ចការអាស៊ាន) ព្រមទាំងមានហត្ថលេខា របស់ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ ។

## ២-សកម្មភាពការប្រារព្ធពិធីទិវាជាតិអំណាន ១១ មីនា ២០១៧

សកម្មភាពនៃទិវាជាតិអំណាន បានប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី០៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ ។ ( សូមមើលតារាងទី១ និងទី២ ក្នុងឧបសម្ព័ន្ធ ស្តីពី កម្មវិធីទិវាជាតិអំណាន )

**ថ្ងៃទី ០៩ ខែមីនា ឆ្នាំ២០១៧**

ជាកម្មវិធីប្រឡងប្រជែងអាន និងសូត្រកំណាព្យ ដើម្បីដណ្តើមជ័យលាភី ថ្នាក់ លេខ១ លេខ២ លេខ៣ ទាំងផ្នែកអាន និងសូត្រកំណាព្យ សម្រាប់ទទួលពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** ។

**១-កម្មវិធីបើក**

**ក**-សមាសភាពគណៈអធិបតី

| | | | |
|---|---|---|---|
| ១. លោកជំទាវ | **ច័ន្ទ** | **ធី** | រដ្ឋលេខាធិការក្រសួងព័ត៌មាន |
| ២. លោកជំទាវ | **ទន់** | **សាអ៊ឹម** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តម បណ្ឌិត | **នៅ** | **ស៊ុន** | អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ |
| ៤. លោក | **វ៉ែន** | **ស៊ុន** | ទីប្រឹក្សាសមាគមអ្នកនិពន្ធខ្មែរ |
| ៥. លោក | **យ៉ាង** | **មុរិន** | ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |
| ៦. លោក | **ស៊ុន** | **ម៉ុណ្ណា** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៧. លោក | **ឃឹម** | **សារិន** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៨. លោក | **ឃិន** | **ធី** | អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៩. លោកស្រី | **គេង** | **សុគន្ធាលក្ខ័** | អធិការមធ្យមសិក្សានៃនា.មចទ |

១០.លោក លោកស្រី ក្រុមការងាររៀបចំទិវាជាតិអំណាន

១១.កុមារ កុមារី ជាបេក្ខជនប្រឡងប្រជែងការអាន និងស្មូតកំណាព្យ

សរុបអ្នកចូលរួមមាន ២០៤ នាក់ ក្នុងនោះស្រីមាន៨៦ នាក់។



**ខ**- មតិសំណេះសំណាលរបស់គណៈអធិបតី

- មតិលោកជំទាវ **ច័ន្ទ ធី** រដ្ឋលេខាធិការក្រសួងព័ត៌មាន

លោកជំទាវ បានបង្ហាញពីបច្ចេកទេសនៃការប្រឡងប្រជែងដើម្បីទទួលបានជ័យលាភី មានដូចជា ៖

. ការបញ្ចេញសូរសំឡេងត្រូវតែចំអក្ខរាវិរុទ្ធ និងច្បាស់លាស់

. កាយវិការ ទឹកមុខ ត្រូវសំដែងឱ្យស្របជាមួយខ្លឹមសារដែលយើងកំពុងស្មូតកំណាព្យ ឬ អានអត្ថបទ

- មតិរបស់លោកជំទាវ **ទន់ សាអ៊ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា



. សាទរចំពោះអ្វីដែលលោកជំទាវរដ្ឋលេខាធិការក្រសួងព័ត៌មានបានលើកឡើង

. លោកជំទាវបានផ្តល់ភាពជឿជាក់ដល់បេក្ខជនក្នុងការផ្តល់ពិន្ទុវាយតម្លៃយ៉ាងសុក្រឹត និងយុត្តិធម៌ ជូនបេក្ខជន។

**២-កម្មវិធីប្រឡងប្រជែងស្មូតកំណាព្យ និងអានអត្ថបទ**

គណៈកម្មការវាយតម្លៃផ្តល់ពិន្ទុ និងបេក្ខជន ត្រូវបានបែងចែកជា២ ក្រុម និងដំណើរការតាមទីតាំងផ្សេងគ្នាដូចខាងក្រោម ៖

*ក-ក្រុមប្រឡងប្រជែងស្ចូតកំណាព្យ បានប្រព្រឹត្តទៅនៅក្នុង*

**មជ្ឈមណ្ឌលវប្បធម៌សម្ដេច ហ៊ុន សែន និងលោកជំទាវ**

**ក.១** សមាសភាពគណៈកម្មការ



១. លោកជំទាវ **ច័ន្ទ ធី** រដ្ឋលេខាធិការក្រសួងព័ត៌មាន

២. លោក **ម៉ែន ស៊ុន** ទីប្រឹក្សាសមាគមអ្នកនិពន្ធខ្មែរ

៣. លោក **យ៉ាវ បូរិន** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

៤. លោក **ស៊ុន ម៉ុណ្ណា** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា អ្នកសម្របសម្រួល

**ក.២** សមាសភាពបេក្ខជន

បេក្ខជនមកពី ២១ រាជធានី ខេត្ត មាន ២១ នាក់ ក្នុងនោះស្រី ១៦ នាក់។ បេក្ខជនទាំងអស់ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៩ ។

**ក.៣** វិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យដាក់ពិន្ទុ

- បេក្ខជនទាំងអស់ត្រូវបានហៅឡើងស្ចូតម្ដងម្នាក់ៗ តាមលំនាំបទ និងខ្លឹមសារដែលបេក្ខជនបានជ្រើសរើសដោយខ្លួនឯង ។
- ការកែលម្អ និងផ្តល់អនុសាសន៍ពីគណៈកម្មការវាយតម្លៃ និងដាក់ពិន្ទុ
- ស្ចូតគោរពតាមលំនាំបទនីមួយៗរបស់កំណាព្យ
- សំឡេងពីរោះក្រអៅក្រអួន សំឡេងមិនដាច់ មិនភ្លាត់ ឬ ភ្លាវនាំឱ្យខុសចង្វាក់ភ្លេង
- លើកដាក់សម្លេងតាមចង្វាក់បទរបស់កំណាព្យ និងទឹកមុខកាយវិការទៅតាមបរិយាកាសនៃបទនីមួយៗ



( រូបថតតំណាង បេក្ខជនស្ចូតកំណាព្យ )

**ក.៤** លទ្ធផល និងចំណាត់ថ្នាក់នៃការប្រឡងប្រជែងស្ចូតកំណាព្យ

| ល,រ | ឈ្មោះ | ភេទ | ថ្នាក់ | មកពីសាលា | ខេត្ត | ពិន្ទុ | ម.ភាគ | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | **ម៉ុន បញ្ញា** | ប្រុស | ទី៩ | វិ.ហស.ជ្រៃហូរញ៉ៅ | កំពង់ស្ពឺ | ២៦,០០ | ៨,៦៦ | **១** |
| ២ | **ស៊ឹម ស៊ាវយី** | ស្រី | ទី៩ | អនុ.ទួលថ្ម | កំពង់ចាម | ២៥,៥០ | ៨,៥០ | **២** |
| ៣ | **ឌន ស៊ីដែន** | ស្រី | ទី៩ | អនុ.តាប៉ោង | កំពង់ធំ | ២៣,០០ | ៧,៦៦ | **៣** |

( សូមមើលតារាងទី៣ ក្នុងឧបសម្ព័ន្ធ ស្តីពី តារាងកំណត់ពិន្ទុ សម្រាប់ការអាន និងស្ចូតកំណាព្យ )

( សូមមើលតារាងទី៤ ក្នុងឧបសម្ព័ន្ធ ស្តីពី ពិន្ទុសរុប មធ្យមភាគ និងចំណាត់ថ្នាក់របស់បេក្ខជនស្ចូតកំណាព្យ )

*ខ-ក្រុមប្រឡងប្រជែងអាន បានប្រព្រឹត្តទៅនៅក្នុងអគារ H ( សាលកុំព្យូទ័រ ) នៃវិទ្យាស្ថានជាតិអប់រំ*

ខ.១ សមាសភាពគណៈកម្មការ

១. លោកជំទាវ **ទន់ សារ៉ុម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

២. លោក បណ្ឌិត **នៅ ស៊ីន** អនុប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ

៣. លោក **ឃិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៤. លោក **ឃឹម សារិន** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា អ្នកសម្របសម្រួល

៥. លោកស្រី **គេខ សុគន្ធាលក្ខ្មី** អធិការមធ្យមសិក្សា

៦. លោក **យូ លក្ខិណា** អនុប្រធានបណ្ណាល័យ



ខ.២ សមាសភាពបេក្ខជន

បេក្ខជនមកពី ២១ រាជធានី ខេត្ត មាន ២១ នាក់ ក្នុងនោះស្រី ២០ នាក់។ បេក្ខជនទាំងអស់ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៦ ។

ខ.៣ វិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យដាក់ពិន្ទុ

- បេក្ខជនទាំងអស់ត្រូវបានហៅឡើងអានម្តងម្នាក់ តាមអត្ថបទដែលគណៈកម្មការបានកំណត់ឱ្យ
- កែលម្អ និងផ្តល់អនុសាសន៍ពីគណៈកម្មការវាយតម្លៃនិងដាក់ពិន្ទុ
- អានអត្ថបទបានលឿន , គោរពឃ្លាឈ្នះបានត្រឹមត្រូវ
- សំឡេងច្បាស់ៗ , អានបានត្រឹមត្រូវតាមសូរបស់ពាក្យ
- មិនខុសពាក្យ មិនរំលងពាក្យ



( រូបថតតំណាង បេក្ខជនអំណាន )

ខ.៤ លទ្ធផល និងចំណាត់ថ្នាក់នៃការប្រឡងប្រជែងអាន

| ល.រ | ឈ្មោះ | ភេទ | ថ្នាក់ | មកពីសាលា | ខេត្ត | ពិន្ទុ | ម.ភាគ | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | **អ៊ីន សុគមន្ធី** | ស្រី | ទី៦ | ប.វាលវង់កំពង់ចាម | កំពង់ចាម | ៣០,០០ | ១០,០០ | **១** |
| ២ | **មុំ ម៉ាលីសារ** | ស្រី | ទី៦ | ប.គំរូស្រុក | បន្ទាយមានជ័យ | ២៨,៥០ | ៩,៥០ | **២** |
| ៣ | **សុវណ្ណា ចរនីត** | ស្រី | ទី៦ | ប.២ ធ្នូ | បាត់ដំបង | ២៧,០០ | ៩,០០ | **៣** |

( សូមមើលតារាងទី៥ ក្នុងឧបសម្ព័ន្ធ ស្តីពី ពិន្ទុសរុប មធ្យមភាគ និងចំណាត់ថ្នាក់របស់បេក្ខជនអានអត្ថបទ )

**ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៧**

ជាកម្មវិធីពិនិត្យ កែលម្អ ណែនាំបច្ចេកទេសបន្ថែមដល់បេក្ខជនជ័យលាភីទាំង៦រូប និងទាំងផ្នែកសូត្រកំណាព្យ និងអានអត្ថបទ និងការតាំងស្តង់ពិព័រណ៍របស់ក្រសួងអប់រំ អង្គការជាតិ អន្តរជាតិ និងក្រុមហ៊ុនផ្សេងៗ។

***១-ការពិនិត្យ កែលម្អ និងណែនាំបច្ចេកទេសដល់បេក្ខជនជ័យលាភី***

ក-សមាសភាពគណៈអធិបតីភាព និងអ្នកចូលរួម

១- លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

២- លោកជំទាវ **ទន់ សារ៉ុម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣- លោក **អេរ សៀម** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៤- លោក **ឃិន ធី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៥- លោក លោកស្រី សាស្រ្តាចារ្យ សាលាមធ្យមសិក្សាវិចិត្រសិល្បៈ

៦- លោក លោកស្រី ក្រុមការងាររៀបចំទិវាជាតិអំណាន និងអង្គការដៃគូអភិវឌ្ឍមួយចំនួន

៧- បេក្ខជនជ័យលាភី និងអាណាព្យាបាល និងគ្រូដឹកនាំរបស់បេក្ខជនជ័យលាភី

ខ-សកម្មភាពពិនិត្យ កែលម្អ និងណែនាំបច្ចេកទេស

-ការអាន និងសូត្រឡើងវិញសារចុះសារឡើង របស់បេក្ខជនទាំងពីរវិញ្ញាសា

- ការកែលម្អបច្ចេកទេសអាន និងសូត្រ ពីថ្នាក់ដឹកនាំក្រសួងអយក. និងពីសាស្រ្តាចារ្យសាលាមធ្យមសិក្សាវិចិត្រសិល្បៈ

*២-ការតាំងស្តង់ពិព័រណ៌*

ទិវាជាតិអំណាន១១ មីនា ឆ្នាំ២០១៧ មានស្តង់ពិព័រណ៌សម្រាប់ការតាំង និងលក់ផលិតផល ចំនួន៣៣ស្តង់ មានដូចជា ស្តង់ក្រសួងអប់រំ អង្គការដៃគូអភិវឌ្ឍ គ្រឹះស្ថានបោះពុម្ព បណ្ណាគារ បណ្ណាល័យ និងស្ថាប័នឯកជនផ្សេងៗចំនួន២៨អង្គភាព ។

( សូមមើលតារាងទី៦ ក្នុងឧបសម្ព័ន្ធ ស្តីពី ឈ្មោះអង្គភាព និងចំនួនស្តង់របស់អង្គភាពនីមួយៗ )

**ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៧**

ជាថ្ងៃប្រារព្ធពិធីទិវាជាតិអំណាន។ លទ្ធផលសកម្មភាព និងការប្រព្រឹត្តទៅមានដូចខាងក្រោម ៖

*១-កម្មវិធីពេលព្រឹក*

**ក- សមាសភាពគណៈអធិបតី និងអ្នកចូលរួម**

១. ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២. ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន

៣.លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

៤. លោកស្រី **អាន ឡឺម៉ៃស្រ្ត** ប្រធានអង្គការយូណេស្កូ

៥. ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ មកពីក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា ក្រសួងបរិស្ថាន

៦. ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្រុមប្រឹក្សាជាតិភាសាខ្មែរ រាជបណ្ឌិត្យសភាកម្ពុជា សមាគមបណ្ណារក្ស និងឯកសារវិទូ និងបណ្ណាល័យជាតិ

៧. ឯកឧត្តម លោកជំទាវ លោក លោកស្រី អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

៨. លោក លោកស្រី បុគ្គលិកអប់រំ មកពីមន្ទីរអប់រំ យុវជន និងកីឡា ២៥ រាជធានី ខេត្ត

៩. លោក លោកស្រី តំណាងអង្គការដៃគូអភិវឌ្ឍ ( អង្គការជាតិ និងអង្គការអន្តរជាតិ )

១០. សិស្ស និស្សិត មកពី វិទ្យាស្ថានជាតិអប់រំ សាលាគរុកោសល្យនិងមត្តេយ្យមជ្ឈឹម វិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យអនុវត្ត ។

១១. កុមារ ជាបេក្ខជនប្រឡងប្រជែងអាន និងសូត្រកំណាព្យ និងមាតាបិតារបស់បេក្ខជនសិស្ស មកពី២៥ រាជធានី ខេត្ត ។

សរុបអ្នកចូលរួមមាន ១៥៣២ នាក់ ក្នុងនោះស្រីមាន ៩៦៣ នាក់ ។



**សមាសភាពក្នុងពិធីទិវាជាតិអំណាន ១១ មីនា ២០១៧**

( សូមមើលតារាងទី៧ ក្នុងឧបសម្ព័ន្ធ ស្តីពី សមាសភាព និងចំនួនអ្នកចូលរួមក្នុងពិធី )

## ខ- ការថ្លែងសុន្ទរកថា

១. សុន្ទរកថារបស់លោកស្រី **អាន ឡឺម៉េស្រ្ត** ប្រធានអង្គការ យូណេស្កូ



ប្រសាសន៍របស់លោកស្រី មានខ្លឹមសារដូចខាងក្រោម ៖

-គាំទ្រ និងកោតសរសើរ ការបង្កើតឱ្យមានជាទិវាជាតិអំណាននេះឡើង ជាពិសេស ការប្រឡងប្រជែងអានអត្ថបទ និងសូត្រកំណាព្យ ។

- អានគឺជាសារៈសំខាន់ក្នុងការស្រាវជ្រាវ និងស្វែងរកព័ត៌មាន

- ប្រទេសជាតិមួយត្រូវពឹងផ្អែកលើជំនាន់យុវវ័យ។

" ***ការអាន នឹងនាំពួកគេមានការអភិវឌ្ឍសមត្ថភាពដល់ខ្លួនឯង និងជួយដល់ការអភិវឌ្ឍសង្គមជាតិ*** "

២. សុន្ទរកថារបស់ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន



ឯកឧត្តមបានបង្ហាញថា ៖

- បច្ចុប្បន្ននេះ ព្រះរាជាណាចក្រកម្ពុជាយើង មានសៀវភៅច្រើនលើសពីឆ្នាំ១៩៧២

- ការអានសៀវភៅមានសារៈប្រយោជន៍ជាងការមើលភាពយន្ត ដោយការមើលភាពយន្ត គឺយើងទទួលពុទ្ធិតែមួយផ្នែក ដោយមានតែខួរក្បាលតែមួយប៉ុណ្ណោះជាអ្នកចាំទទួល ឯការអានគឺ ខួរក្បាលបានធ្វើការ ភ្នែកបានមើល និងដៃបានកត់ត្រា ។

- ឯកឧត្តមបានសំដែងការសាទរ និងសប្បាយចិត្តក្នុងការរៀបចំទិវាជាតិអំណាននេះ

- ការមើល Face book ច្រើន វានឹងបង្ករគ្រោះថ្នាក់ ព្រោះអ្នកមើលមិនបានវិភាគ ឃើញប៉ុន្មានដឹងបានត្រឹមតែប៉ុណ្ណឹង ដែលជាទូទៅព័ត៌មានក្នុងសង្គម Face book វាជាព័ត៌មាន

ខ្លី និងបែបសង្ខេប និងអ្វីដែលសំខាន់ជាងនេះទៀត គឺ អ្នកប្រើប្រាស់ និងមើលតែអ្វីដែលខ្លួនចូលចិត្ត ។

" *ការអានច្រើន នឹងយល់ច្រើន ដឹងច្រើន ពេលនោះនាំឱ្យមានការយោគយល់ បានកាន់តែច្រើន* "

៣. សុន្ទរកថារបស់លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ



ខ្លឹមសារនៃប្រសាសន៍របស់លោកជំទាវ មានដូចខាងក្រោម ៖

- គាំទ្រទាំងស្រុង ដល់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការផ្តួចផ្តើមឱ្យមានការរៀបចំទិវាជាតិអំណាននេះឡើង ដែលជាការបំផុស ឱ្យមានការអប់រំប្តូរទំលាប់ពីអ្វីដែលមិនសូវចូលចិត្តអាន មកជាការចាប់អារម្មណ៍ និងចូលចិត្តអាន និងសន្យានឹងចូលរួមជាមួយក្រសួងអប់រំ ក្នុងការប្រារព្ធទិវាជាតិអំណាននេះលើកក្រោយៗទៀត ។
- ការអានមានសារៈសំខាន់ណាស់ ដោយសារការអានបានធ្វើឱ្យយើងយល់ដឹងពីខ្លឹមសារនៃសិលាចារិក និងសាស្ត្រាស្លឹករឹត។
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានរៀបចំពិព័រណ៍សៀវភៅជាច្រើនដងមកហើយ ដែលនេះ បំណងសំខាន់ដើម្បីបំផុស ទាក់ទាញឱ្យមានការអាន។
- ការអាន គឺជាការដោះស្រាយ ជាការកំសាន្ត និងនាំឱ្យមានគំនិតពិចារណា
- សូមឱ្យស្មារតីនៃការអានសៀវភៅ កើតមានដល់អ្នកចូលរួមគ្រប់រូប និងជួយបំផុសឱ្យអ្នកជុំវិញខ្លួន មានការអាន ដើម្បីសង្គមយើងមានការរីកចម្រើន ។

" *គ្មានអ្នកកាន់ការងារណាមួយ ដែលជោគជ័យក្នុងជីវិត ដោយគ្មានការអាននោះទេ* "

៤. សុន្ទរកថារបស់ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា



ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី មានខ្លឹមសារដូចខាងក្រោម ៖

- អរគុណ និងគាំទ្រដល់ក្រុមការងាររៀបចំទិវាជាតិអំណាន ដែលបានប្រឹងប្រែងក្នុងការរៀបចំទិវាជាតិអំណាន ១១ មីនា ២០១៧ នាឆ្នាំនេះ និងអរគុណដល់ឯកឧត្តម លោកជំទាវ និងអ្នកចូលរួមដែលបានអញ្ជើញមកពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ លោកគ្រូ អ្នកគ្រូ និងសិស្សនិស្សិត ដែលបានចូលរួមនាឱកាសនេះ។
- ការរៀបចំទិវាជាតិអំណានឆ្នាំនេះ គឺជាឆ្នាំកំណើតរបស់សម្តេចសង្ឃរាជ **ជួន ណាត** ហើយដែល សម្តេច ជាអ្នកអភិរក្សអក្សរសាស្ត្រខ្មែរ ជាពិសេសការបង្កើតបាន វចនានុក្រមខ្មែរ ។
- ការរៀបចំទិវាជាតិអំណានឆ្នាំនេះ មានទិដ្ឋភាពធំជាងការរៀបចំទិវាជាតិអំណានឆ្នាំ២០១៦ ដោយពេលនេះ យើងមាន អ្នកសារព័ត៌មានច្រើន អ្នកចូលរួមក៏ច្រើនជាងឆ្នាំមុន ឯការរៀបចំពិធីក៏មានភាពអធិកអធមជាងដែរ។
- ប្រធានបទទិវាជាតិអំណាន " **អានដើម្បីភាពសុខដុមនៃជីវិត** " មានន័យថា យើងអានដើម្បីបំពេញតម្រូវការ ៖

  ១-តម្រូវការសាមញ្ញ ( ហូបចុក ញុំា តម្រូវការសារវន្ត )

  ២-តម្រូវការសុវត្ថិភាព

  ៣-តម្រូវការស្រឡាញ់ ការថ្នាក់ថ្នម

  ៤-តម្រូវការឱ្យមានការគោរព

  ៥-តម្រូវការកម្រិតខ្ពស់ គឺតម្រូវការចំណីប្រាជ្ញាស្មារតី ជាពិសេសក្តីដឹងអនេក ទោះ

ការបាត់បង់នូវរូបរាងកាយក្នុងលោកក៏កេរ្តិ៍ឈ្មោះនៅបានរក្សាទុកជាប់ជានិច្ច។
ដូចជា សម្ដេចសង្ឃ **ជួន ណាត** ជាដើម ។

- ដើម្បីបានការអភិវឌ្ឍដល់កម្រិតកំពូល គឺពឹងផ្អែកលើការអាន។ ដូចនេះការនិពន្ធសៀវភៅជារឿងមួយដ៏សំខាន់ដែលអ្នកនិពន្ធត្រូវចាប់អារម្មណ៍ ថាតើយើងគួរសរសេរយ៉ាងដូចម្ដេចដើម្បីអូសទាញការអានរបស់អ្នកអាន។
- ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនៅក្នុងកម្មវិធីសិក្សា នៅការតែងសេចក្ដី និងសរសេរតាមអាន ដែលនេះជាបំណងមួយនៅក្នុងការជំរុញនៃការអាន។

" *សូមឱ្យការអាន ស្ថិតក្នុងអារម្មណ៍របស់ជំនាន់យុវវ័យ* "

" *ការអាន ជួយយើងឱ្យឆ្លងកាត់ផុតទុក្ខកង្វល់* "

## គ. ការបង្ហាញ ពីបុព្វបទ ស្តីពី សារៈសំខាន់នៃការអាន

ដោយលោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា



ប្រសាសន៍របស់លោកជំទាវមានខ្លឹមសារដូចខាងក្រោម ៖

- អក្សរសាស្ត្របានចាប់ផ្ដើម នៅសម័យព្រះបាទកៅឌិណ្យ
- អក្សរសាស្ត្រទាក់ទងផ្ទាល់ និងលទ្ធិសាសនា និងពិសេសអក្សរសាស្ត្រ ត្រូវបានចារិកនៅសិលាចារិក សម្រាប់ការបង្ហាញដល់អ្នកជុំវិញ ដើម្បីអានយល់ពីខ្លឹមសារទាំងនោះ។
- ការស្រមើស្រមៃប្រកបដោយទស្សនវិជ្ជារបស់អ្នកកវីនិពន្ធជំនាន់មុនៗ ពិតជាបានទាញអារម្មណ៍ ឱ្យអ្នកអាន ចូលចិត្តតាមដាន និងរឹតតែចង់អានហើយអានទៀត ។ ដូចនេះ ស្នើសុំឱ្យអ្នកនិពន្ធ និងអ្នកជំនាញផ្សេងៗ គួរយកចិត្តទុកដាក់លើស្នាដៃរបស់អ្នកនិពន្ធល្បីៗ ដើម្បីជាបទពិសោធន៍ក្នុងការតាក់តែងនិពន្ធ។
- អក្សរសាស្ត្ររីកចម្រើន ដោយសារព្រះមហាក្សត្រ ឬ មេដឹកនាំ យកចិត្តទុកដាក់លើកសរសើរទឹកចិត្តកវីនិពន្ធ។
- អក្សរសាស្ត្រ និងការអាន ត្រូវបានបាត់បង់ទាំងស្រុង ដោយសារសង្គ្រាមបែកបាក់ ការញុះញង់។ បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ និងសង្គមជាតិមានការអភិវឌ្ឍ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ លើការអានឡើងវិញ រហូតមានអនុក្រឹត្យលេខ១២០ នេះ ។

" *សូមឱ្យស្មារតីទិវាជាតិអំណាន ស្ថិតនៅក្នុងក្រអៅបេះដូងរបស់ប្រជាជនកម្ពុជា* "

" *វិជ្ជាសម្បត្តិ ចរិយាសម្បត្តិ និងបំណិនសម្បទា ទាំង៣នេះ កើតឡើងដោយសារការអាន* "

## ឃ. ការសូត្រកំណាព្យបទពាក្យ៧ " **មច្ឆាជាតិ** " ដកស្រង់ពីរឿងសព្វសិទ្ធិ

សូត្រដោយលោកស្រី **សេក សាវី** សាស្ត្រាចារ្យសាលាភូមិន្ទវិចិត្រសិល្បៈ

## ង. ការប្រកាសពានរង្វាន់ជ័យលាភីអំណាន និងសូត្រកំណាព្យ

បេក្ខជនជ័យលាភីក្នុងទិវាជាតិអំណាន ១១ មីនា ២០១៧ ផ្នែកសូត្រកំណាព្យមាន៣រូប និងអានអត្ថបទមាន៣រូប ដូចមានឈ្មោះក្នុងរូបថតខាងក្រោម៖




ជ័យលាភីស្មូតកំណាព្យ




ជ័យលាភីអានអត្ថបទ

## ច. ការអានអត្ថបទ និងស្មូតកំណាព្យរបស់បេក្ខជនជ័យលាភី

បេក្ខជនជ័យលាភីទាំង៦នាក់ ត្រូវបានអនុញ្ញាតឱ្យអានអត្ថបទ និងស្មូតកំណាព្យឡើងវិញ ដើម្បីជូនដល់អង្គពិធីទាំងមូលបានស្តាប់ និងអាចដឹងបានពីកម្រិតជំនាញ និងកោសល្យរបស់បេក្ខជនម្នាក់ៗ។





( រូបថតតំណាង បេក្ខជនជ័យលាភីស្មូតកំណាព្យ និងអានអត្ថបទ )

## ឆ. ពិធីប្រគល់ពានរង្វាន់ និងប្រគល់ប្រាក់រង្វាន់លើកទឹកចិត្ត

បេក្ខជនជ័យលាភីទាំង៦នាក់ ត្រូវបានទទួលពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** និងប្រាក់រង្វាន់លើកទឹកចិត្តពី ឯកឧត្តម លោកជំទាវគណៈអធិបតី និងបានទទួលការអបអរសាទរពីអង្គពិធីទាំងមូល។

**ជ័យលាភីស្មូតកំណាព្យ**



( **ពានរង្វាន់លេខ ២** )



( **ពានរង្វាន់លេខ ១** )



( **ពានរង្វាន់លេខ ៣** )

ប្រាក់រង្វាន់លើកទឹកចិត្ត

- ជ័យលាភីលេខ១ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៤,០០០,០០០ ៛
- ជ័យលាភីលេខ២ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣,០០០,០០០ ៛
- ជ័យលាភីលេខ៣ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២,០០០,០០០ ៛



ជ័យលាភីអានអត្ថបទ



( ពានរង្វាន់លេខ ២ )



( ពានរង្វាន់លេខ ១ )



( ពានរង្វាន់លេខ ៣ )

ប្រាក់រង្វាន់លើកទឹកចិត្ត

- ជ័យលាភីលេខ១ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ៣,០០០,០០០ ៛
- ជ័យលាភីលេខ២ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ២,០០០,០០០ ៛
- ជ័យលាភីលេខ៣ ទទួលបានពាន១
  និងប្រាក់រង្វាន់លើកទឹកចិត្តចំនួន ១,០០០,០០០ ៛





**៥. ការស្មូតកំណាព្យ បទ " និរាសអក្ខរ "**

កំណាព្យបទនេះ ត្រូវបានស្មូតដោយ លោក **ឃិន ឃាង** សាស្ត្រាចារ្យសាលាមធ្យមសិក្សាវិចិត្រសិល្បៈ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

*២-កម្មវិធីពេលល្ងាច*

ជាកម្មវិធី វេទិការបស់វាគ្មិនល្បីៗដែលពោរពេញដោយបទពិសោធន៍។ កម្មវិធីនេះមាន វេទិកាអំណាន និងការពិភាក្សាលើប្រធានបទមួយចំនួន។

**ក- សមាសភាពចូលរួម**

១. ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា



២. ឯកឧត្តម លោកជំទាវ លោក លោកស្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ប្រធាន អនុប្រធាន និងមន្ត្រី អង្គភាពក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា

៣-ព្រះសង្ឃ

៤-និស្សិត សាកលវិទ្យាល័យបញ្ញាសាស្ត្រ

៥- គរុសិស្សសាលាគរុកោសល្យ និងមត្តេយ្យមជ្ឈឹម

៦- សិស្សវិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាល័យអនុវត្ត និង អនុវិទ្យាល័យចតុមុខ

៧- បេក្ខជនប្រឡងប្រជែងការអាន និងស្មូតកំណាព្យ ២៥ រាជធានី ខេត្ត

សរុបអ្នកចូលរួមមានប្រមាណ ៨០០ នាក់ ក្នុងនោះស្រីមាន ៥១២ នាក់ ។

**ខ- វេទិកាអំណាន**

**១. អ្នកសម្របសម្រួល**



- លោក បណ្ឌិត **រស់ សុខាចា** អគ្គនាយករងនៃ អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- លោកស្រី **សេង ហ្សានីន**

**២. សមាសភាពវាគ្មិន**

- លោក បណ្ឌិត **សំអេរ អង្គារតន៍** អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ
- លោកស្រី **កង កល្យាណ** ពិធីការិនី និង ជាផលិតករកម្មវិធីទូរទស្សន៍ CTN and CNC
- លោកស្រី **ខែក ខេមរ៉ាត** អគ្គនាយិកាក្រុមហ៊ុន Blue Media

**៣-វិធីសាស្ត្រ**

- អ្នកសម្របសម្រួលជាអ្នកដឹកនាំវេទិកា ដោយផ្តល់ឱកាសបញ្ចេញមតិជូនវាគ្មិនម្នាក់ៗក្នុងថេរវេលាស្មើគ្នា និងការពិនិត្យពេលវេលា និងសំយោគបញ្ចប់លទ្ធផលនៃកិច្ចបញ្ចេញមតិក្នុងវេទិកាទាំងមូល។
- ផ្តល់ឱកាសជូនអ្នកចូលរួមបានសួរពីអ្វីដែលពួកគេចង់ដឹងទាក់ទងនឹងប្រធានបទដែលបានលើកឡើងដោយវាគ្មិនម្នាក់ៗ ។

- វាគ្មិនឆ្លើយតបទៅនឹងសំណួររបស់អ្នកចូលរួម

៤-ប្រធានបទ " **ការអាន និងសរសេរក្នុងយុគសម័យបណ្តាញសង្គម** "

**៥-សកម្មភាព និងលទ្ធផល**

- បង្ហាញពីប្រវត្តិការងាររបស់វាគ្មិនទាំង៣ នាក់ខាងលើ

- មតិរបស់វាគ្មិន ទាំង៣ ៖

លោក បណ្ឌិត **សំអោ អង្គារតន៍**

. អាន គឺជា ការមើលអក្សរ ជាការមើលប្រកបសញ្ញាសំគាល់អក្សរ ជាស័ព្ទ ឬ សូរសៀង។

. យើងត្រូវកំណត់ឱ្យបានច្បាស់ ថាតើយើងអានដើម្បីអ្វី និងអ្វីដែលត្រូវអាន

. យើងជាអ្នកប្រើប្រាស់បណ្តាញសង្គម ត្រូវចេះពិចារណា ពីអ្វីដែលត្រូវអាន ហើយព័ត៌មានដែលមាននៅក្នុងបណ្តាញសង្គមមិនមានខ្លឹមសារគ្រប់គ្រាន់ទេ ដោយខ្លឹមសារនោះខ្លី សង្ខេប មិនពិស្តារ។ មានតែបណ្ណាល័យទេ ដែលជាកន្លែងមួយសម្រាប់ការសិក្សាស្រាវជ្រាវទូលំទូលាយ ។ ដូច្នេះ ពេលទំនេរ យើងត្រូវចំណាយពេលវេលាឱ្យបានច្រើនដើម្បីចូលបណ្ណាល័យ ។

" ការប្រើប្រាស់បណ្ណាល័យជាការសំខាន់ និងចាំបាច់របស់អ្នកសិក្សា "

" *អានច្រើន ជាការតភ្ជាប់ពីអតីតកាលទៅអនាគតកាល* "

លោកស្រី **ភង ភល្សាណា**

- អានឱ្យបានច្រើន ទើបដឹងពាក្យសំដីដែលត្រូវនិយាយ

- ការប្រើប្រាស់ប្រព័ន្ធសង្គមវាទទួលផលច្រើន ប៉ុន្តែវាអាស្រ័យលើអ្នកប្រើ

" *កំសោយនៃការអាន យើងនឹងជួបឧបសគ្គក្នុងជីវិត* "

លោកស្រី **ខែក ខេមរ៉ាត**

- អ្នកនិពន្ធត្រូវតែអានឱ្យបានច្រើន ទើបយល់បានពីទឹកចិត្តរបស់អ្នកអាន ធ្វើឱ្យមានការគាំទ្រនូវស្នាដៃនៃការនិពន្ធរបស់ខ្លួន។

- ការអាន គឺធ្វើឱ្យមានភាពជោគជ័យក្នុងជីវិត ។

- ការប្រើប្រាស់សង្គម Face book មានផលវិជ្ជមាន និងអវិជ្ជមាន តែសំខាន់អ្នកប្រើប្រាស់ត្រូវកំណត់គោលដៅឱ្យច្បាស់ ថាតើយើងប្រើដើម្បីអ្វី ហើយអ្វីដែលយើងត្រូវទាញយក ។

" *គ្មានអ្នកដឹកនាំណាម្នាក់ ទទួលបានជោគជ័យដោយមិនឆ្លងកាត់ការអាននោះទេ* "

**សំណួរ-ចម្លើយ**

សំណួរ លោក **ភេង ម៉ុន** និស្សិតវិទ្យាស្ថានជាតិអប់រំ

១-តើធ្វើដូចម្តេច ដើម្បីឱ្យការអានសៀវភៅ មានការចូលចិត្តអាន ដូចការចូលចិត្តមើលអាន Face book ?

២-តើធ្វើដូចម្តេចដើម្បីឱ្យក្មេងចូលចិត្តអានសៀវភៅ

ចម្លើយ ៖១-ដើម្បីឱ្យការអានសៀវភៅ មានការចូលចិត្តអាន ដូចការចូលចិត្តមើលអាន Face book ៖

. ការនិពន្ធគួរត្រូវបានលើកកំពស់ និងអ្នកនិពន្ធត្រូវស្វែងយល់ចិត្តរបស់អ្នកអាន

. បង្កើនគុណភាពសៀវភៅ

. ក្នុងការបង្រៀនរបស់គ្រូ គួរដាក់កិច្ចការស្រាវជ្រាវឱ្យបានច្រើនដល់សិស្ស

២-ដើម្បីឱ្យក្មេងចូលចិត្តអានសៀវភៅ ៖

. គួរតែចាប់ផ្តើមពីខ្លួនយើងផ្ទាល់ដើម្បីបង្ហាញគម្រូដល់កុមារ ពិសេសអាណាព្យាបាលសិស្ស

. គួរតែឪពុកម្តាយឆ្លៀតពីការងារដើម្បីជួយបង្រៀនកូន ទោះជាឪពុកម្តាយមិនចេះក៏ត្រូវចេះសួរនាំ ដើម្បីដឹងពីការសិក្សារបស់កូន ជាពិសេសការបំពេញកិច្ចការរបស់សាលាដែលគ្រូបានដាក់ឱ្យធ្វើ។

មតិសរុបរបស់លោក បណ្ឌិត **រស់ សុវាចា**

- ការអានដើម្បីទទួលបានជោគជ័យ យើងត្រូវស្គាល់ខ្លួនឱ្យបានច្បាស់ មានន័យថា តើយើងជាមនុស្សចូលចិត្តអានបែបណា ៖ ចូលចិត្តអានក្នុងបរិយាកាសទូទៅ ស្ងាត់ ស្ងាត់រួមមានភ្លេង សរសេរបណ្តើរស្តាប់បណ្តើរ សរសេរផងបរិភោគផង ។
- ការបណ្តុះការអានគឺ គឺផ្តើមពីខ្លួនឯង និងគ្រួសារ ( ស្គាល់ខ្លួនឯង ធ្វើសង្គ្រាមខ្លួនឯង ដើម្បីឈ្នះខ្លួនឯង ) និងមិនថាកន្លែងណានោះទេ ។

**គ- ការពិភាក្សាលើប្រធានបទ**

**១. អ្នកសម្របសម្រួល**



- លោក បណ្ឌិត **ឌី ខាំបូលី** ប្រធាននាយកដ្ឋានគោលនយោបាយ
- លោកស្រី **សេខ ហ្សានីន**

**២. សមាសភាពវាគ្មិន**

- ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
- លោក **ហុក សិទ្ធិ** ប្រធានអង្គការស៊ីប៉ា និងជាប្រធានសមាគមបណ្ណារក្ស និងឯកសារវិទូកម្ពុជា
- លោកស្រី **ពាន់ តួចបុប្ផា** អ្នកនិពន្ធល្បី

**៣-វិធីសាស្ត្រ**

- អ្នកសម្របសម្រួលជាអ្នកដឹកនាំវេទិកា ដោយផ្តល់ឱកាសបញ្ចេញមតិជូនវាគ្មិនម្នាក់ៗក្នុងថេរវេលាស្មើគ្នា និងការពិនិត្យពេលវេលា និងសំយោគបញ្ចប់លទ្ធផលនៃកិច្ចបញ្ចេញមតិក្នុងវេទិកាទាំងមូល។
- ផ្តល់ឱកាសជូនអ្នកចូលរួមបានសួរពីអ្វីដែលពួកគេឆ្ងល់ចង់ដឹងទាក់ទងនឹងប្រធានបទដែលបានលើកឡើងដោយវាគ្មិនម្នាក់ៗ ។
- វាគ្មិនឆ្លើយតបទៅនឹងសំណួររបស់អ្នកចូលរួម

**៤-ប្រធានបទ " តើអ្វីជាសារប្រយោជន៍នៃការអាន "**

**៥-សកម្មភាព និងលទ្ធផល**

- បង្ហាញពីប្រវត្តិការងាររបស់វាគ្មិនទាំង៣ នាក់ខាងលើ
- មតិរបស់វាគ្មិន ទាំង៣ ៖

ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន**

. ប្រវត្តិនៃការកកើតអក្សរ ( នៅប្រទេសក្រិក ) កើតមករាប់ពាន់ឆ្នាំមកហើយ

. សម័យអង្គរ យើងមានសាស្ត្រាស្លឹករឹត សិលាចារិក ដើម្បីចារទុកបង្ហាញដល់អ្នកជំនាន់ក្រោយពីអ្វីដែលបានកើតមកកន្លង និងចង់ឱ្យមនុស្សជំនាន់ក្រោយបានដឹង ។

. ការបកស្រាយអត្ថន័យ " អានដើម្បីភាពសុខដុមនៃជីវិត " ( ដូចខាងលើ )

. ឪពុក ម្តាយ ជាសាលាមត្តេយ្យសិក្សារបស់កូន

. ការដាក់កិច្ចការរបស់គ្រូ វាជាប្រសិទ្ធភាពមួយដើម្បីទំលាប់ក្នុងការរបស់សិស្ស

" *អានដើម្បីដឹងពីអ្វីដែលយើងត្រូវធ្វើនៅពេលខាងមុខ និងអ្វីដែលនឹងត្រូវកើតឡើងនាពេលខាងមុខ* "

ដូចនេះការអាន អាចឱ្យយើងដឹងបានថា ៖

- យើងមកពីណា
- យើងនៅឯណា
- យើងនឹងធ្វើអ្វីនៅពេលខាងមុខ

លោក **ហុក សិទ្ធិ**

- ការអានកើតចេញពីការឆ្ងល់
- ប្រទេសរីកចម្រើន គេបានជំរុញខ្លាំងលើផ្នែក សំណេរ អាន និងការងារបណ្ណាល័យ

" *ការមិនបានអាន គឺមិនមានអ្វីដើម្បីនិយាយតតាំងជាមួយគេឡើយ* "

លោកស្រី **ពាន់ ត្នួចបុប្ផា**

- លោកស្រី មានថ្ងៃនេះ ដោយសារការអាន
- ការអាន ដំបូងវាជាព្រហ្មទណ្ឌ តែដើម្បីឱ្យការអានទទួលបានជោគជ័យយើងគួរចាប់ផ្តើមការអាន ពីអ្វីដែលតាមចំណង់ចំណូលចិត្ត។
- ការអានធ្វើឱ្យយើងមានចំណេះដឹងច្រើន ដែលអាចឱ្យយើងដឹងបានពីភពផ្សេងៗ។

" *រាល់អ្នកអានទាំងអស់ មិនប្រាកដក្លាយជាមេ ឬ អ្នកដឹកនាំទេ ប៉ុន្តែមេ ឬ អ្នកដឹកនាំត្រូវតែអានដើម្បីប្រសិទ្ធរបស់ខ្លួន* "

### *៣-ការតាំងសមិទ្ធិផល និងសកម្មភាព*

ស្តង់ទាំង ៣៣ ដែលគ្រប់គ្រងដោយ២៨ ស្ថាប័ន មានដូចបានរៀបរាប់ខាងលើ មានតាំងលក់ បង្ហាញ និងមានសកម្មភាពដូចខាងក្រោម ៖

#### ក-ការតាំងលក់សមិទ្ធិផល

ការតាំងបង្ហាញ និងលក់សមិទ្ធិផលរបស់ស្តង់ទាំងអស់មានលក្ខណៈប្រហាក់ប្រហែលគ្នា ដូចជា ការតាំងបង្ហាញ និងលក់សៀវភៅអាន សម្ភារៈសិក្សា សម្ភារៈក្មេងលេង អាវយឺត និងសម្ភារៈផ្សេងទៀតមួយចំនួន ។ សម្ភារៈទាំងអស់នេះមានដាក់តាំងនៅ ស្តង់របស់បណ្តាអង្គការដៃគូអភិវឌ្ឍ និងក្រុមហ៊ុន អ្នកទស្សនាអាចជាវយកទៅអាន និងប្រើប្រាស់តាមតម្រូវការ និងចំណង់ចំណូលចិត្តរបស់ខ្លួន។ ដោយឡែកស្តង់ របស់ក្រសួងអប់រំ មានតាំងបង្ហាញពីឯកសារជាសមិទ្ធិផលរបស់អង្គភាព ក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡា អ្នកទស្សនាអាចខ្ចីយកទៅថតចម្លង និងអានបាន ដោយទំនាក់ទំនង និងធ្វើពាក្យស្នើសូមខ្ចីនៅបណ្ណាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងលោកជំទាវកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** បឹងត្របែក ក្នុងបរិវេណវិទ្យាល័យបឹងត្របែក។ ក្រៅពីនេះ នៅមានស្តង់ធំៗចំនួន២ សម្រាប់កុមារ និងសម្រាប់អ្នកទស្សនា ថតរូបអនុស្សាវរីយ៍ក្នុងពិធីទិវាជាតិអំណាន ១១ មីនា ។





### ខ-សកម្មភាពស្តង់

ស្តង់ទាំងអស់ត្រូវបានចូលទស្សនា ជាវសៀវភៅ ថតរូប និងអាន ដោយឯកឧត្តម លោកជំទាវ សមាជិក នៃអង្គពិធីទិវាជាតិអំណានទាំងមូល  ដែលមានទិដ្ឋភាពបង្ហាញដូចមានក្នុងរូបថតខាងក្រោម ៖





( សកម្មភាពថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា )




( សកម្មភាពថ្នាក់ដឹកនាំក្រសួងពាក់ព័ន្ធ និងអ្នកចូលរួម )



( សកម្មភាពកុមារ )




( សកម្មភាពថតរូបរបស់អ្នកចូលរួម )

## IV. **សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

### **ក-សេចក្តីសន្និដ្ឋាន**

អ្នកចូលរួមទាំងអស់ មានចំណាប់អារម្មណ៍ និងសប្បាយរីករាយ ចំពោះទិវាជាតិអំណាននេះ ដោយពួកគេបានបង្ហាញភាពយល់កាន់ច្បាស់ថែមទៀត អំពី សារប្រយោជន៍នៃការអាន និងពីការរៀបចំទិវាជាតិអំណាន ពិសេសលទ្ធផលនៃស្នាដៃរបស់កូនខ្មែរដែលជាអ្នកនិពន្ធជំនាន់ថ្មី តាមរយៈកំណើននៃសៀវភៅអាន ។

លទ្ធផលនៃទិវាជាតិអំណាន យើងទទួលបានសារអប់រំជាច្រើនពីឯកឧត្តម លោកជំទាវ និងវាគ្មិន ព្រមទាំងបទពិសោធន៍ ថែមទៀតសម្រាប់ការរៀបចំទិវាជាតិអំណាន និងពិធីផ្សេងៗទៀត សម្រាប់ឆ្នាំបន្តបន្ទាប់។

### **ខ-អនុសាសន៍**

- យកចិត្តទុកដាក់បន្ថែមទៀតចំពោះគ្រូ ពិសេសវិធីសាស្ត្រ និងការយកចិត្តទុកដាក់របស់គ្រូទៅលើការអនុវត្តជំហានទាំង៥ ដែលជំហានទី៥ ជាចំណែកមួយជំរុញឱ្យសិស្សស្រាវជ្រាវ និងអានច្រើន ដើម្បីបំពេញកិច្ចការដែលគ្រូបានដាក់ឱ្យធ្វើ ។

- យកចិត្តទុកដាក់ការបន្ថែមទៀត លើការងារដឹកនាំ គ្រប់គ្រងរបស់នាយកសាលារៀន ជាពិសេសការទំនាក់ទំនងជាមួយសហគមន៍ ដោយឡែកជាមួយអាណាព្យាបាល មាតាបិតាសិស្ស ដើម្បីឱ្យពួកគាត់បានតាមលទ្ធផលសិក្សារបស់កូន និងការជួយបង្រៀនដល់កូនតាមលទ្ធភាពរបស់ពួកគាត់ដែលអាចធ្វើទៅបាន។

- បង្កើនការយកចិត្តទុកដាក់បន្ថែមទៀត លើការនិពន្ធសៀវភៅសិក្សា ដូចជា ការជ្រើសរើសអ្នកនិពន្ធ ការពិនិត្យគុណភាពសៀវភៅ ជាដើម ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០១៧

បានឃើញ និងឯកភាព | **អ្នកធ្វើរបាយការណ៍**

**ប្រធាននាយកដ្ឋាន**

V. **ឧបសម្ព័ន្ធ**

តារាងទី១

**កម្មវិធីប្រឡងប្រជែងអានអត្ថបទ និងស្មូតកំណាព្យ**
**ថ្ងៃទី០៩-១០ ខែមីនា ឆ្នាំ២០១៧**
**វិទ្យាស្ថានជាតិអប់រំ**

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧

| **ម៉ោង** | **បរិយាយ** | **អ្នកទទួលខុសត្រូវ** |
|---|---|---|
| ៧:០០-៧:៣០ | ការអញ្ជើញមកដល់របស់សមាជិកគណៈកម្មការ និងបេក្ខជន | ដឹកនាំដោយលោកជំទាវ **ទន់ សារអ៊ឹម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា |
| ៧:៣០-៨:០០ | ប្រជុំគណៈកម្មការវាយតម្លៃដាក់ពិន្ទុ | |
| ៨:០០-១១:៣០ | កម្មវិធីប្រឡងអាន និងស្មូតកំណាព្យ | |
| ១១:៣០-១៣:៣០ | សម្រាកថ្ងៃត្រង់ | |
| ១៣:៣០-១៦:៣០ | កម្មវិធីប្រឡងអាន និងស្មូតកំណាព្យបន្ត | |
| ១៦:៣០-១៧:០០ | ប្រជុំគណៈកម្មការវាយតម្លៃសរុប ធ្វើចំណាត់ថ្នាក់សម្រេច | |

ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧

| **ម៉ោង** | **បរិយាយ** | **អ្នកទទួលខុសត្រូវ** |
|---|---|---|
| ៧:០០-៨:០០ | ការអញ្ជើញមកដល់របស់គណៈកម្មការ និងបេក្ខជនជ័យលាភី | ដឹកនាំដោយ ១-លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ២-លោកជំទាវ **ទន់ សារអ៊ឹម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា |
| ៨:៣០-៩:៣០ | ប្រជុំគណៈកម្មការវាយតម្លៃ និងបេក្ខជនជ័យលាភី | |
| ៩:៣០-១១:៣០ | រាយការណ៍ និងឧទ្ទេសនាមបេក្ខជនជ័យលាភីជូនថ្នាក់ដឹកនាំក្រសួងអយក. ហាត់សមអានអត្ថបទ និងស្មូតកំណាព្យ ត្រៀមបង្ហាញ និងទទួលពានរង្វាន់ **សម្តេចតេជោ ហ៊ុន សែន** នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ | |
| ១១:៣០-១៣:៣០ | សម្រាកថ្ងៃត្រង់ | |
| ១៣:៣០-១៧:០០ | បន្តការងារដែលនៅសេសសល់ និងការងារចាំបាច់ | |

<u>តារាងទី២</u>

## កម្មវិធីទិវាជាតិអំណានថ្ងៃ១១ មីនា ២០១៧

ប្រធានបទ " **អានដើម្បីភាពសុខដុមនៃជីវិត** "

វិទ្យាស្ថានជាតិអប់រំ

| ម៉ោង | បរិយាយ | អ្នកទទួលខុសត្រូវ |
|---|---|---|
| ៧:០០-៧:៣០ | ការអញ្ជើញមកដល់របស់សមាជិក សមាជិកា | នា.រដ្ឋបាល |
| ៧:៣០-៨:០០ | ថ្នាក់ដឹកនាំក្រសួង និងភ្ញៀវកិត្តិយសអញ្ជើញមកដល់ | នា.រដ្ឋបាល/ទវអ |
| ៨:០០-៨:១០ | ចាប់ផ្តើមកម្មវិធី និងគោរពទង់ជាតិ (ច្រៀងរួមដល់ចប់) | លោក **រស់ សូវិចា**<br>ល.ស **សេខ ហ្សានីន** |
| ៨:១០-៨:២០ | ការសម្តែងរបាំជូនពរ | |
| ៨:២០-៩:៣០ | សុន្ទរកថាថ្លែងដោយៈ<br>- លោកស្រី **អាន ឡឺម៉ែស្ត្រ** ប្រធានអង្គការយូណេស្កូ<br>- ឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន<br>- លោកជំទាវ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ<br>- ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | |
| ៩:៣០-៩:៥០ | បុព្វបទស្តីពីសារៈសំខាន់នៃការអាន ដោយលោកជំទាវ **ទន់ សាអ៊ឹម**<br>អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | |
| ៩:៥០-១០:១០ | ស្មូតកំណាព្យបទពាក្យ៧ " **មច្ឆាជាតិ** " ដកស្រង់ពីរឿងសព្វសិទ្ធិ<br>(សាស្ត្រាចារ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ) | |
| ១០:១០-១០:៣០ | ប្រកាសពានរង្វាន់ជ័យលាភីអំណាន និងស្មូតកំណាព្យ | |
| ១០:៣០-១០:៤៥ | អានអត្ថបទគតិលោក ឬរឿងព្រេង (ដោយជ័យលាភីលេខ ១ សិស្សថ្នាក់ទី៦) | |
| ១០:៤៥-១១:០០ | ស្មូតកំណាព្យបទបន្ទោលកាក " **ល្បើក ដុច និងត្រី** "<br>(ដោយជ័យលាភីលេខ ១ សិស្សថ្នាក់ទី៩) | |
| ១១:០០-១១:២០ | ពិធីចែករង្វាន់ជ័យដល់លាភីពីលេខ១ ដល់លេខ៣<br>- ប្រគល់រង្វាន់ជ័យលាភីអំណាន<br>- ប្រគល់រង្វាន់ជ័យលាភីស្មូតកំណាព្យ | |
| ១១:២០-១១:៣៥ | ស្មូតកំណាព្យបទ " **និរាសអង្គរ** " (សាស្ត្រាចារ្យក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ) | |
| ១១:៣៥-១២:០០ | ពិព័រណ៍សៀវភៅ | នាអកស |
| ១២:០០-១៤:០០ | **សម្រាកថ្ងៃត្រង់** | |
| ១៤:០០-១៥:០០ | វេទិកាអំណាន " **ការអាន និងសរសេរក្នុងយុគសម័យបណ្តាញសង្គម** "<br>ដោយលោកស្រី **ភខ កល្យាណ** ពិធីការនីព័ត៌មាន និងផលិតកម្មវិធី CNC/CTN<br>លោក **សំអេ អង្គារតន៍** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ<br>លោកស្រី **ខែក ខេមរ៉ាត** អគ្គនាយិកាក្រុមហ៊ុន Blue Media | លោក **រស់ សូវិចា**<br>ល.ស **សេខ ហ្សានីន** |
| ១៥:០០-១៦:០០ | ការពិភាក្សាលើប្រធានបទៈ<br>តើការអានមានសារៈប្រយោជន៍យ៉ាងណាខ្លះចំពោះអាជីពរបស់អ្នក?<br>" **បទបង្ហាញនូវភាពជោគជ័យដែលទទួលបានពីចូលចិត្តអានសៀវភៅ** "<br>- ឯកឧត្តម បណ្ឌិត **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា<br>- លោក **ហុក សុទ្ធិ** ប្រធានអង្គការស៊ីប៉ា/ប្រធានសមាគមបណ្ណារក្ស និងឯកសារវិទូកម្ពុជា<br>- លោកស្រី **ពាន់ ត្បួងបុប្ផា** អ្នកនិពន្ធល្បី | លោក បណ្ឌិត<br>**ឌី ខាំបូលី**<br>ល.ស **សេខ ហ្សានីន** |
| ១៦:៣០-១៧:០០ | **នាទីកម្សាន្ត** ៖ ការបង្ហាញម៉ូតសៀវភៅ | ល.ស **សេខ ហ្សានីន**<br>កញ្ញា **គឹម ឌីណា** |

តារាងទី៣

## តារាងពិន្ទុលម្អិត

ការអានអត្ថបទ

| ល-រ | លក្ខណៈវិនិច្ឆ័យ | ពិន្ទុ | ផ្សេងៗ |
|---|---|---|---|
| ១ | អានអត្ថបទបានលឿន | **២** | |
| | • អានអត្ថបទបានលឿន | ១ | |
| | • គោរពឃ្លា ល្បះ បានត្រឹមត្រូវ | ១ | |
| ២ | សំឡេងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ | **៣** | |
| | • សំឡេងច្បាស់ៗ | ១ | |
| | • អានត្រឹមត្រូវតាមសូររបស់ពាក្យ | ២ | |
| ៣ | ពាក្យមិនខុស មិនរំលងពាក្យ | **៤** | |
| | • មិនខុសពាក្យ | ២ | |
| | • មិនរំលងពាក្យ | ២ | |
| ៤ | ឥរិយាបថសមរម្យ | **១** | |
| **ពិន្ទុសរុប** | | ១០ | |

ការសូត្រកំណាព្យ

| ល-រ | លក្ខណៈវិនិច្ឆ័យ | ពិន្ទុ | ផ្សេងៗ |
|---|---|---|---|
| ១ | សូត្រកំណាព្យតាមលំនាំបទនីមួយៗរបស់កំណាព្យ | ៤ | |
| ២ | សំឡេងពីរោះក្រអៅក្រអួន | ២ | |
| ៣ | សំឡេងមិនដាច់ មិនភ្លាត់ ឬ ភ្លាំនាំឱ្យខុសចង្វាក់ | ១ | |
| ៤ | លើក ដាក់ សំឡេងតាមចង្វាក់បទរបស់កំណាព្យ | ២ | |
| ៥ | ទឹកមុខ កាយវិការ ទៅតាមបរិយាកាសនៃបទនីមួយៗ | ១ | |
| **សរុបពិន្ទុ** | | ១០ | |

## តារាងទី៤

# តារាងពិន្ទុសរុប មធ្យមភាគ និងចំណាត់ថ្នាក់ របស់បេក្ខជនប្រឡងប្រជែងសួតកំណាព្យ

| ល.រ | ឈ្មោះ | ភេទ | ថ្នាក់ | មកពីសាលា | ខេត្ត | ពិន្ទុ | ម.ភាគ | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | គង់ វិសាខា | ស្រី | ទី៩ | វិ.ស្វាយរៀង | ស្វាយរៀង | 18.50 | 6.66 | លេខ 11 |
| ២ | គង់ ស្រីនាថ | ស្រី | ទី៩ | វិទ្យាល័យអង្គរ | សៀមរាប | 20.50 | 6.88 | លេខ 9 |
| ៣ | ឆែម រស្មី | ស្រី | ទី៩ | វិ.ឈើទាលជ្រុំ | តាកែវ | 22.00 | 7.33 | លេខ 4 |
| ៤ | ជួប ស្រីពេជ្រ | ស្រី | ទី៩ | វិ.ព្រះសុរាម្រឹត | កំពង់ឆ្នាំង | 19.50 | 6.50 | លេខ 14 |
| ៥ | ជួន សាម៉ឺឌី | ប្រុស | ទី៩ | អនុ.សម្ដេចឪ | ព្រះសីហនុ | 20.00 | 6.66 | លេខ 11 |
| ៦ | ជួន កញ្ញា | ស្រី | ទី៩ | វិ.ហ.ស មណ្ឌលគីរី | មណ្ឌលគីរី | A | A | A |
| ៧ | ជិន លីអេង | ស្រី | ទី៩ | វិ.សម្ដេចឪ សម្ដេចម៉ែ | រតនគីរី | A | A | A |
| ៨ | ឈឿម គឹមលីម | ស្រី | ទី៩ | វិ.សកពនរ.អូរអំបិល | បន្ទាយមានជ័យ | 19.00 | 6.33 | លេខ 17 |
| ៩ | ឌន ចាន់ពិសី | ប្រុស | ទី៩ | អនុ.ពោធិសាត់ | ពោធិសាត់ | 21.00 | 7.00 | លេខ 8 |
| ១០ | ឌន ស៊ីដែន | ស្រី | ទី៩ | អនុ.តាប៉ោង | កំពង់ធំ | 23.00 | 7.66 | **លេខ 3** |
| ១១ | ថា ពៅពីន | ប្រុស | ទី៩ | វិ. ហ.ស កោះស្រឡាយ | ស្ទឹងត្រែង | 17.50 | 5.83 | លេខ 19 |
| ១២ | ទីណា សុផាលាភ | ស្រី | ទី៩ | វិទ្យាល័យបាភ្នំ | ព្រៃវែង | 18.00 | 6.00 | លេខ 18 |
| ១៣ | នៅ គិមហង្ស | ស្រី | ទី៩ | វិ. ហ.ស ជ្រៃហូរញ្ញៅ | ឧត្ដរមានជ័យ | 16.50 | 5.50 | លេខ 21 |
| ១៤ | ប៊ុន បញ្ញា | ប្រុស | ទី៩ | វិ.ហ.ស ជ្រៃហូរញ្ញៅ | កំពង់ស្ពឺ | 26.00 | 8.66 | **លេខ 1** |
| ១៥ | ប៉ុន សូនីតា | ស្រី | ទី៩ | វិ.ហាស សេរីភាព | កណ្ដាល | 20.00 | 6.66 | លេខ 11 |
| ១៦ | បាំង លីហេង | ប្រុស | ទី៩ | អនុ. ហាស.ក្រចេះក្រុង | ក្រចេះ | A | A | A |
| ១៧ | មឿង សុមាត្រ | ស្រី | ទី៩ | អនុ.ជីផាត | កោះកុង | 17.50 | 5.83 | លេខ 19 |
| ១៨ | រ៉ិត ជីរិន | ស្រី | ទី៩ | អនុវិទ្យាល័យរោងរ៉ែង | កំពត | 22.00 | 7.33 | លេខ 4 |
| ១៩ | វុត្ថា ភីរ៉ា | ស្រី | ទី៩ | អនុ. សោហ៊ី | បាត់ដំបង | 22.00 | 7.33 | លេខ 4 |
| ២០ | ស៊ឹម ស៊ាន់យី | ស្រី | ទី៩ | អនុ.ទួលថ្ម | កំពង់ចាម | 25.50 | 8.50 | **លេខ 2** |
| ២១ | ស៊ុន យុន្នី | ស្រី | ទី៩ | វិ.ជាស៊ីមតែ្បងមានជ័យ | ព្រះវិហារ | 19.50 | 6.50 | លេខ 14 |
| ២២ | ហៀន គឹមហេង | ស្រី | ទី៩ | អនុ.រោងរ៉ែង | ប៉ៃលិន | A | A | A |
| ២៣ | ហេង ស៊ីរម៉ា | ស្រី | ទី៩ | អនុ.បរន. ហាស.ចរិយាវង្ស | កែប | 19.50 | 6.50 | លេខ 14 |
| ២៤ | ហ៊ឹម សុធារី | ស្រី | ទី៩ | វិ.ហាសបរន.ផ្សារដើមថ្កូវ | ភ្នំពេញ | 20.50 | 6.83 | លេខ 9 |
| ២៥ | ហៀន លក្ខិណា | ស្រី | ទី៩ | អនុ.ហ.ស ចារថ្មី | ត្បូងឃ្មុំ | 21.50 | 7.16 | លេខ 7 |

តារាងទី៥

## តារាងពិន្ទុសរុប មធ្យមភាគ និងចំណាត់ថ្នាក់ របស់បេក្ខជនប្រឡងប្រជែងអានអត្ថបទ

| ល.រ | គោត្តនាម-នាម | ភេទ | ថ្នាក់ | មកពីសាលា | ខេត្ត | ពិន្ទុ | ម.ភាគ | ចំ.ថ្នាក់ |
|---|---|---|---|---|---|---|---|---|
| ១ | គឹន សុវណ្ណា | ប | ទី៦ | បឋមសិក្សាប្រជាកុមារស្វង | ត្បូងឃ្មុំ | 23.50 | 7,83 | លេខ 13 |
| ២ | គ្រូក ដាលីន | ស | ទី៦ | បឋមសិក្សាហ.ស ចាក់អង្រែ | ភ្នំពេញ | 23.00 | 7.66 | លេខ 17 |
| ៣ | ឃន ស្រីខួច | ស | ទី៦ | បឋមសិក្សាសម្តេចឪ-ម៉ែ | ស្ទឹងត្រែង | 22.50 | 7.50 | លេខ 22 |
| ៤ | ង៉ោ សៀវហ៊ុយ | ស | ទី៦ | បឋមសិក្សាកំពង់ធំក្រុង | កំពង់ធំ | 25.00 | 8.33 | លេខ 10 |
| ៥ | ជឹង ស៊ីវលិ | ស | ទី៦ | បឋម.ហ.សសែនមនោរម្យ | មណ្ឌលគីរី | A | A | A |
| ៦ | ណា គឹមឡាំង | ស | ទី៦ | បឋម.ព្រែកប្រសព្វលើ | ក្រចេះ | 21.50 | 7.16 | លេខ 23 |
| ៧ | ធូ ចាន់ធី | ស | ទី៦ | បឋមសិក្សាអូរតាពុក | ប៉ៃលិន | A | A | A |
| ៨ | នាង ធិតា | ស | ទី៦ | បឋមសិក្សាពោធិសាត់ | ពោធិសាត់ | 23.50 | 7.83 | លេខ 13 |
| ៩ | នុយ  ពិសិដ្ឋរង្សី | ស | ទី៦ | បឋមសិក្សាវត្តស្ទឹង | កំពត | 25.00 | 8.33 | លេខ 10 |
| ១០ | ប៉ូ ឈឿនវ៉ាណា | ស | ទី៦ | បឋមសិក្សាមុខនាគ | សៀមរាប | 23.00 | 7.66 | លេខ 17 |
| ១១ | ភាព តារាវត្តី | ស | ទី៦ | បឋមសិក្សាផ្សារលើ | ព្រះសីហនុ | 24.00 | 8.00 | លេខ 12 |
| ១២ | មុំ ម៉ាលីសារ | ស | ទី៦ | បឋមសិក្សាគំរូស្រុក | បន្ទាយមានជ័យ | 28.50 | 9.50 | **លេខ 2** |
| ១៣ | រិត ម៉ារីឌី | ស | ទី៦ | បឋមសិក្សាអនុវត្ត | ស្វាយរៀង | 23.00 | 7.66 | លេខ 17 |
| ១៤ | លី លក្ខិណា | ស | ទី៦ | បឋម. ហ.ស កែវក្រសាំង | កែប | 23.00 | 7.66 | លេខ17 |
| ១៥ | លូន ចាម | ស | ទី៦ | បឋមសិក្សា បុរីកម្មករ៤ | រតនគីរី | 26.00 | 8.66 | លេខ 8 |
| ១៦ | វ៉ុន ណារតន៍ | ស | ទី៦ | បឋមសិក្សាម្រុំខាងជើង | កំពង់ស្ពឺ | 26.50 | 8.83 | លេខ 4 |
| ១៧ | សុវណ្ណ វរនីត | ស | ទី៦ | សាលាបឋមសិក្សា ២ធ្នូ | បាត់ដំបង | 27.00 | 9.00 | **លេខ 3** |
| ១៨ | សៀក សូលីកា | ស | ទី៦ | បឋមសិក្សាគំរូក្រុង | កំពង់ឆ្នាំង | 27.50 | 8.83 | លេខ 4 |
| ១៩ | សំភូ  សោភ័ណ្ឌ | ស | ទី៦ | បឋមសិក្សាសំរោង | ឧត្តរមានជ័យ | 23.00 | 7.66 | លេខ 17 |
| ២០ | ស៊ុន ស្រីថ | ស | ទី៦ | សាលាអន្តរជាតិ ហ្វូមឃីដស៍ | ព្រះវិហារ | 23.50 | 7.83 | លេខ 13 |
| ២១ | ស៊ាន សុខណា | ស | ទី៦ | បឋមសិក្សាព្រៃល្វា | តាកែវ | 26.50 | 8.83 | លេខ 4 |
| ២២ | សុខុន ពៅធីតា | ស | ទី៦ | បឋម. បរន. ហ.ស អនុវត្ត | កណ្តាល | 25.50 | 8.50 | លេខ 9 |
| ២៣ | អ៊ឹង សុភមន្នី | ស | ទី៦ | បឋមសិក្សាវាលវង់ | កំពង់ចាម | 30.00 | 10.00 | **លេខ 1** |
| ២៤ | ហង្ស សីលា | ប | ទី៦ | បឋមសិក្សាព្រៃវែងក្រុង | ព្រៃវែង | 26.50 | 8.83 | លេខ 4 |
| ២៥ | អោក សម្បត្តិមុនី | ប | ទី៦ | បឋមសិក្សាទីរួមខេត្ត | កោះកុង | 23.50 | 7.83 | លេខ 13 |

**<u>តារាងទី៦</u>**

## បញ្ជីរាយឈ្មោះអង្គភាព និងចំនួនស្តង់

| ល.រ | ឈ្មោះស្ថាប័ន | ចំនួនស្តង់ |
|---|---|---|
| ១. | ក្រសួងអប់រំ (ស្តង់អំណោយ និងស្តង់ពិពណ៌សៀវភៅ) | (១) |
| ២. | អង្គការ Room To Read | (១) |
| ៣. | អង្គការ UNESCO | (១) |
| ៤. | អង្គការ Sipar | (១) |
| ៥. | អង្គការ SVA | (១) |
| ៦. | គ្រឹះស្ថានបោះពុម្ព Under The Roof Publishing | (១) |
| ៧. | ដំណើរកៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ | (១) |
| ៨. | គ្រឹះស្ថានផលិតសៀវភៅប្រភពប្រាជ្ញា | (១) |
| ៩. | ធនធានសិក្សា (កំពង់ចាម) | (១) |
| ១០. | គ្រឹះស្ថានបោះពុម្ពផ្សាយ Nokor An Edition | (១) |
| ១១. | Comics Art Printing | (១) |
| ១២. | Ming Book | (២) |
| ១៣. | Discover Your Greatness | (១) |
| ១៤. | ស្រលាញ់សៀវភៅ | (១) |
| ១៥. | Angkor Printing House | (២) |
| ១៦. | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | (២) |
| ១៧. | Father Books | (១) |
| ១៨. | Washinton DC School | (១) |
| ១៩. | ក្រុមហ៊ុន យូខេន រីន | (១) |
| ២០. | ដាំដើមឈើ | (២) |
| ២១. | You Care Book | (១) |
| ២២. | Scholar Library | (១) |
| ២៣. | បណ្ណាល័យសាកលវិទ្យាល័យកម្ពុជា | (១) |
| ២៤. | សង្គប្បអនុវត្តន៍ លោកគ្រូ ស៊ីថា | (១) |
| ២៥. | Aide et Action | (២) |
| ២៦. | Sethkun Bookstore | (១) |
| ២៧. | ប៉ែ ណៃត | (១) |
| ២៨. | Wisdom Book | (១) |

តារាងទី៧

# បញ្ជីរាយសមាសភាព និងចំនួនចូលរួម ទិវាជាតិអំណាន
# ១១ មីនា ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ

| លរ | អង្គភាព | ចំ.ចូលរួម | ផ្សេងៗ |
|---|---|---|---|
| I. | **ក្រសួងអប់រំ យុវជន និងកីឡា** | | |
| ១ | ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា | 20 | នាក់ |
| | សរុប(១) | 20 | នាក់ |
| II. | **អង្គភាពក្រោមឱវាទក្រសួងអយក** | | |
| ២ | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | 5 | នាក់ |
| ៣ | នាយកដ្ឋានរដ្ឋបាល | 10 | នាក់ |
| ៤ | នាយកដ្ឋានហិរញ្ញវត្ថុ | 10 | នាក់ |
| ៥ | នាយកដ្ឋានបុគ្គលិក | 10 | នាក់ |
| ៦ | នាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន | 10 | នាក់ |
| ៧ | នាយកដ្ឋាននីតិកម្ម | 10 | នាក់ |
| ៨ | នាយកដ្ឋានសំណង់ | 10 | នាក់ |
| ៩ | នាយកដ្ឋានសម្ភារៈ និងទ្រព្យសម្បត្តិរដ្ឋ | 10 | នាក់ |
| ១០ | នាយកដ្ឋានសម្ភារៈ និងអាហារូបករណ៍ | 10 | នាក់ |
| ១១ | អគ្គនាយកដ្ឋានអប់រំ | 5 | នាក់ |
| ១២ | នាយកដ្ឋានអប់រំកុមារតូច | 10 | នាក់ |
| ១៣ | នាយកដ្ឋានបឋមសិក្សា | 10 | នាក់ |
| ១៤ | នាយកដ្ឋានអប់រំមធ្យមសិក្សាចំណេះទូទៅ | 10 | នាក់ |
| ១៥ | នាយកដ្ឋានអប់រំតម្រង់ទិសវិជ្ជាជីវៈ | 10 | នាក់ |
| ១៦ | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | 10 | នាក់ |
| ១៧ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | 10 | នាក់ |
| ១៨ | នាយកដ្ឋានសុខភាពសិក្សា | 10 | នាក់ |
| ១៩ | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | 10 | នាក់ |
| ២០ | គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ | 10 | នាក់ |
| ២១ | អគ្គនាយកដ្ឋានឧត្តមសិក្សា | 2 | នាក់ |
| ២២ | នាយកដ្ឋានឧត្តមសិក្សា | 10 | នាក់ |
| ២៣ | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | 10 | នាក់ |
| ២៤ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | 20 | នាក់ |
| ២៥ | សាកល.ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | 20 | នាក់ |
| ២៦ | វិទ្យាស្ថានជាតិអប់រំ | 10 | នាក់ |
| ២៧ | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | 10 | នាក់ |
| ២៨ | គណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | 8 | នាក់ |
| ២៩ | **អគ្គនាយកដ្ឋានយុវជន** | 3 | នាក់ |
| ៣០ | នាយកដ្ឋានយុវជន | 10 | នាក់ |

| | | | |
|---|---|---|---|
| ៣១ | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌល | 10 | នាក់ |
| ៣២ | **អគ្គនាយកដ្ឋានកីឡា** | 3 | នាក់ |
| ៣៣ | នាយកដ្ឋានអប់រំកាយ និងកីឡា | 10 | នាក់ |
| ៣៤ | នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត | 10 | នាក់ |
| ៣៥ | វិទ្យាស្ថានអប់រំកាយ និងកីឡា | 10 | នាក់ |
| ៣៦ | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | 10 | នាក់ |
| ៣៧ | **អគ្គាធិការដ្ឋាន** | 3 | នាក់ |
| ៣៨ | នាយកដ្ឋានធានាគុណភាពអប់រំ | 10 | នាក់ |
| ៣៩ | អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ | 10 | នាក់ |
| ៤០ | **អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ** | 3 | នាក់ |
| ៤១ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | 10 | នាក់ |
| ៤២ | នាយកដ្ឋានគោលនយោបាយ | 10 | នាក់ |
| ៤៣ | នាយកដ្ឋានផែនការ | 10 | នាក់ |
| ៤៤ | នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ | 10 | នាក់ |
| ៤៥ | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | 10 | នាក់ |
| ៤៦ | អង្គភាពលទ្ធកម្ម | 3 | នាក់ |
| ៤៧ | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម | 10 | នាក់ |
| | **សរុប(២)** | **425** | **នាក់** |
| III. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត | | | |
| ៥៧ | មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ | 8 | នាក់ |
| ៥៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កណ្ដាល | 8 | នាក់ |
| ៥៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ព្រៃវែង | 8 | នាក់ |
| ៦០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ស្វាយរៀង | 7 | នាក់ |
| ៦១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ចាម | 8 | នាក់ |
| ៦២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ត្បូងឃ្មុំ | 6 | នាក់ |
| ៦៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ក្រចេះ | 7 | នាក់ |
| ៦៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ស្ទឹងត្រែង | 7 | នាក់ |
| ៦៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត មណ្ឌលគិរី | 6 | នាក់ |
| ៦៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត រតនគិរី | 6 | នាក់ |
| ៦៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ធំ | 7 | នាក់ |
| ៦៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត សៀមរាប | 7 | នាក់ |
| ៦៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ព្រះវិហារ | 7 | នាក់ |
| ៧០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ឧត្តមានជ័យ | 6 | នាក់ |
| ៧១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត បន្ទាយមានជ័យ | 7 | នាក់ |
| ៧២ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ប៉ៃលិន | 6 | នាក់ |
| ៧៣ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ពោធិ៍សាត់ | 7 | នាក់ |
| ៧៤ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត បាត់ដំបង | 10 | នាក់ |
| ៧៥ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ឆ្នាំង | 7 | នាក់ |

| | | | |
|---|---|---|---|
| ៧៦ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ស្ពឺ | 7 | នាក់ |
| ៧៧ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កោះកុង | 6 | នាក់ |
| ៧៨ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត ព្រះសីហនុ | 7 | នាក់ |
| ៧៩ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពត | 7 | នាក់ |
| ៨០ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កែប | 6 | នាក់ |
| ៨១ | មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត តាកែវ | 8 | នាក់ |
| | **សរុប(៣)** | **176** | **នាក់** |
| IV.ក្រសួង/ស្ថាប័នពាក់ព័ន្ធ | | | |
| ៨២ | គណៈអភិបាលរាជធានីភ្នំពេញ | 1 | នាក់ |
| ៨៣ | ក្រសួងព័ត៌មាន | 1 | នាក់ |
| ៨៤ | ក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ | 1 | នាក់ |
| ៨៥ | ក្រសួង ធម្មការ និងសាសនា | 1 | នាក់ |
| ៨៦ | ក្រសួង បរិស្ថាន | 1 | នាក់ |
| ៨៧ | ក្រុមប្រឹក្សាជាតិភាសាខ្មែរ | 1 | នាក់ |
| ៨៨ | បណ្ណាល័យជាតិ | 1 | នាក់ |
| ៨៩ | រាជបណ្ឌិតសភាកម្ពុជា | 1 | នាក់ |
| ៩០ | សមាគមបណ្ណារក្ស និងឯកសារវិទូកម្ពុជា | 1 | នាក់ |
| | **សរុប(៤)** | **9** | **នាក់** |
| V.ដៃគូអភិវឌ្ឍ(អង្គការជាតិ និងអន្តរជាតិ) | | | |
| ៩១ | អង្គការ ស៊ីប៉ា | 6 | នាក់ |
| ៩២ | អង្គការ រូមធូរីដ | 6 | នាក់ |
| ៩៣ | អង្គការសន្តិស្ម័គ្រចិត្ត | 6 | នាក់ |
| ៩៤ | អង្គការមូលនិធិអាស៊ី | 2 | |
| ៩៥ | អង្គការ ឆាលហ្វាន់កម្ពុជា | 2 | នាក់ |
| ៩៦ | អង្គការ ភ្លែនអន្តរជាតិកម្ពុជា | 5 | នាក់ |
| ៩៧ | អង្គការ យូណេស្កូ | 4 | នាក់ |
| ៩៨ | អង្គការយូនីសេហ្វ | 2 | នាក់ |
| ៩៩ | អង្គការសង្គ្រោះកុមារ | 3 | នាក់ |
| ១០០ | អង្គការ UNDP | 1 | នាក់ |
| ១០១ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ | 1 | នាក់ |
| ១០២ | អង្គការ Child Rights Foundation | 1 | នាក់ |
| ១០៣ | ស្ថានទូតអាមេរិក | 1 | នាក់ |
| ១០៤ | ស្ថានទូតអង់គ្លេស | 1 | នាក់ |
| ១០៥ | ស្ថានទូតចិន | 1 | នាក់ |
| ១០៦ | ស្ថានទូតកូរ៉េ | 1 | នាក់ |
| ១០៧ | ស្ថានទូតជប៉ុន | 1 | នាក់ |
| ១០៨ | ស្ថានទូតអាឡឺម៉ង់ | 1 | នាក់ |
| ១០៩ | ស្ថានទូតវៀតណាម | 1 | នាក់ |
| ១១០ | អង្គការខេមរា | 1 | នាក់ |

| | | | |
|---|---|---|---|
| ១១១ | អង្គការគ្រួសារថ្មី | 1 | នាក់ |
| ១១២ | អង្គការ World Vision Cambodia | 1 | នាក់ |
| ១១៣ | អង្គការ Aid et Action  Cambodia | 1 | នាក់ |
| ១១៤ | អង្គារ CARE | 2 | នាក់ |
| ១១៥ | អង្គការ World Education | 1 | នាក់ |
| | **សរុប(៥):** | **53** | **នាក់** |
| VI. សិស្ស -និស្សិត | | | |
| ១១៦ | វិទ្យាស្ថានជាតិអប់រំ | 47 | នាក់ |
| ១១៧ | វិទ្យាល័យព្រះស៊ីសុវត្ថិ | 120 | នាក់ |
| ១១៨ | វិទ្យាល័យ អនុវត្ត | 250 | នាក់ |
| | **សរុប(៦):** | **417** | **នាក់** |
| **សរុបរួម** | | **1100** | |

<u>រូបភាពទី៨</u>

រូបថតប័ណ្ណផ្ទត់






<u>រូបភាពទី៩</u>

សារអប់រំ















## VI . ឯកសារយោង

- អនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពី ទិវាជាតិអំណាន។
- លិខិតលេខ ៥៧៨ សជណ-អវ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពី ការកំណត់គោលការណ៍ក្នុងការផ្តល់ប្រាក់រង្វាន់ជូនជ័យលាភី ក្នុងការប្រឡងអាន សូត្រកំណាព្យ តែងនិពន្ធ និងការប្រសិទ្ធនាមពានរង្វាន់ក្នុងទិវាជាតិអំណាន។
- សេចក្តីណែនាំលេខ ០៥ អយក.សណន ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការប្រារព្ធទិវាជាតិអំណាន។
- លិខិតលេខ ៦០៧ អយក.អកស ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី សំណើសុំទីកន្លែងរៀបចំប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៧ ។
- លិខិតលេខ ០៨ អយក.សសរ ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំការរៀបចំទិវាជាតិអំណាន។
- សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពី ការរៀបចំទិវាជាតិអំណានឆ្នាំ២០១៧ ក្រោមប្រធានបទ " អានដើម្បីភាពសុខដុម " ដែលប្រារព្ធនាថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៧ នៅវិទ្យាស្ថានជាតិអប់រំ ។
- លិខិតបង្គាប់ការលេខ ៣៦ អកស ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ របស់នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ស្តីពី ការចាត់តាំងមន្ត្រីនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ជាគណៈកម្មការទទួលខុសត្រូវក្នុងការរៀបចំ ប្រារព្ធទិវាជាតិអំណាន ១១ មីនា ២០១៧ ។




